អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

ថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១២

# សេចក្តីប្រកាសព័ត៌មាន

## សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីការវាយតម្លៃសាជាថ្មីទៅលើសម្បទារបស់ អៀង ធីរិទ្ធ ក្នុងការចូលរួមការជំនុំជម្រះ

នៅថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១២ អង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្តីសម្រេចរបស់ខ្លួនស្តីពីការវាយតម្លៃសាជាថ្មីទៅលើសម្បទារបស់ជនជាប់ចោទ អៀង ធីរិទ្ធ ក្នុងការចូលរួមការជំនុំជម្រះ។ ដោយផ្អែកលើរបាយការណ៍ និងសក្ខីកម្មរបស់អ្នកជំនាញវេជ្ជសាស្ត្រដែលតែងតាំងដោយតុលាការ អង្គជំនុំជម្រះសាលាដំបូងសូមបញ្ជាក់ជាថ្មីនៅថ្ងៃនេះ ទៅលើសេចក្តីសន្និដ្ឋានរបស់ខ្លួនពីមុនដែលថា ជនជាប់ចោទ អៀង ធីរិទ្ធ ទទួលរងជំងឺកោសិកាចុះទ្រុឌទ្រោមទៅៗ (ស្រដៀងនឹងជំងឺវង្វេងស្មារតី Alzheimer) ហើយគាត់ពុំមានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមការជំនុំជម្រះទេ។ អ្នកជំនាញបានបញ្ជាក់ថា នាពេលនេះ ជម្រើសនៃការព្យាបាលទាំងអស់ត្រូវបានប្រើប្រាស់អស់ហើយ ហើយការចុះខ្សោយផ្នែកបញ្ញាស្មារតីរបស់ជនជាប់ចោទ ទំនងជាមិនអាចវិលត្រឡប់មកដូចដើមវិញបានទេ។ ដោយហេតុថា ពុំមានក្តីរំពឹងថា ជនជាប់ចោទអាចនឹងចូលរួមការជំនុំជម្រះនាពេលខាងមុខបាន អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ពីការលើកការចោទប្រកាន់ប្រឆាំងនឹងជនជាប់ចោទ អៀង ធីរិទ្ធ នៅក្នុងសំណុំរឿង ០០២ និងផ្អាកកិច្ចដំណើរការនីតិវិធីប្រឆាំងរូបគាត់ដោយគ្មានពេលកំណត់។ នៅក្នុងកាលៈទេសៈទាំងនេះ និងដូចដែលសហព្រះរាជអាជ្ញា និងមេធាវីការពារក្តីបានទទួលស្គាល់រួចហើយ អង្គជំនុំជម្រះមានកាតព្វកិច្ចចេញសេចក្តីបង្គាប់ឲ្យដោះលែងជនជាប់ចោទពីមន្ទីរឃុំឃាំង។

ដោយសារកិច្ចដំណើរការនីតិវិធីប្រឆាំង អៀង ធីរិទ្ធ បានផ្អាកដោយគ្មានពេលកំណត់ អង្គជំនុំជម្រះសាលាដំបូងពុំមានមូលដ្ឋានផ្លូវច្បាប់គ្រប់គ្រាន់ ដើម្បីកំណត់លក្ខខណ្ឌដោយបង្ខំទៅលើការដោះលែងរូបគាត់ទេ។ ក្នុងករណីណាក៏ដោយលក្ខខណ្ឌដោយបង្ខំនឹងមានការលំបាកក្នុងការអនុវត្ត ដោយសារសមត្ថភាពផ្លូវចិត្តរបស់ជនជាប់ចោទ។ លក្ខខណ្ឌវេជ្ជសាស្ត្ររបស់គាត់ធានាថា គាត់នឹងពុំមានសមត្ថភាពក្នុងការចងចាំ ឬ

អនុវត្តទៅតាមលក្ខខណ្ឌបានទេ។ ទោះជាយ៉ាងណាក្តី អង្គជំនុំជម្រះសាលាដំបូងយល់ស្របនឹងសហព្រះរាជអាជ្ញាដែលថា វិធានការមួយចំនួនបន្ទាប់ពីដោះលែង អៀង ធីរិទ្ធ នៅតែមានភាពសមរម្យ។ ហេតុនេះ អង្គជំនុំជម្រះសាលាដំបូងក្រើនរម្លឹកដល់ជនជាប់ចោទនូវកាតព្វកិច្ចរបស់ខ្លួន មិនជ្រៀតជ្រែកក្នុងកិច្ចការរដ្ឋបាលរបស់តុលាការ ដូចជា ការទាក់ទងទៅសាក្សី ជនរងគ្រោះ ឬជនជាប់ចោទផ្សេងទៀត (លើកលែងតែស្វាមីគាត់ អៀង សារី)។ អង្គជំនុំជម្រះក៏បានស្នើមិនឲ្យគាត់ចាកចេញពីទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ឲ្យជូនដំណឹងទៅការិយាល័យរដ្ឋបាល អ.វ.ត.ក ចំពោះការផ្លាស់ប្តូរអាសយដ្ឋាន ហើយមិនឲ្យគាត់ប្រាស្រ័យទាក់ទងជាមួយបណ្តាញសារព័ត៌មាន ពាក់ព័ន្ធនឹងកិច្ចដំណើរការនីតិវិធីនៅ អ.វ.ត.ក។ ដោយបច្ចុប្បន្ននេះ ជំងឺ Alzheimer ជាជំងឺមិនអាចព្យាបាលបាន ហើយពុំមានជម្រើសព្យាបាលណាមួយនោះ អង្គជំនុំជម្រះសាលាដំបូងមិនបានបង្គាប់ឲ្យធ្វើការវាយតម្លៃផ្នែកវេជ្ជសាស្ត្របន្ថែមទៀតទៅលើជនជាប់ចោទទេ។ ទោះជាយ៉ាងណាក្តី អង្គជំនុំជម្រះសាលាដំបូងយល់ស្របក្នុងការពិគ្រោះយោបល់ជាមួយអ្នកជំនាញវេជ្ជសាស្ត្រដែលតែងតាំងដោយតុលាការប្រចាំឆ្នាំ ដើម្បីស្វែងរកឲ្យឃើញថាតើមានការព្យាបាលថ្មីៗផ្នែកវេជ្ជសាស្ត្រ ដើម្បីឲ្យអ្នកជំនាញអាចវាយតម្លៃថា ជនជាប់ចោទអាចមានសម្បទាក្នុងការចូលរួមការជំនុំជម្រះបាន។ ដោយហេតុថា លទ្ធភាពនៃការព្យាបាលជំងឺ Alzheimer គឺជាការលើកឡើងបែបស្មានៗទាំងស្រុងនោះ ចំណុចនេះមិនអាចបង្កើតជាមូលដ្ឋានសម្រាប់បន្តការឃុំខ្លួនជនជាប់ចោទទៀតទេ។

គួរគូសបញ្ជាក់ថា សេចក្តីសន្និដ្ឋានពីសម្បទាមិនគ្រប់គ្រាន់ក្នុងការចូលរួមការជំនុំជម្រះ មិនមែនជាសេចក្តីសន្និដ្ឋានពីពិរុទ្ធភាព ឬភាពគ្មានទោសរបស់ជនជាប់ចោទ អៀង ធីរិទ្ធ ទេ ហើយវាក៏ពុំមានអានុភាពជាការដកបទចោទប្រឆាំងនឹងជនជាប់ចោទរូបនេះដែរ។

សេចក្តីសម្រេចស្តីពីការវាយតម្លៃជាថ្មីទៅលើសម្បទារបស់ជនជាប់ចោទ អៀង ធីរិទ្ធ ក្នុងការចូលរួមការជំនុំជម្រះ បន្ទាប់ពីមានសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១១។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖

**លោកស្រី Yuko Maeda**
មន្ត្រីផ្នែកកិច្ចការសាធារណៈ UNAKRT
ទូរស័ព្ទ៖ +៨៥៥(0)១២ ៤៨៨ ៣១៩
ទូរស័ព្ទការិយាល័យ៖ +៨៥៥ (0)២៣ ៨៦១ ៦៣៩
អ៊ីមែល៖ maeday@un.org

**លោក នេត្រ ភក្ត្រា**
មន្ត្រីអ្នកនាំពាក្យ
ទូរស័ព្ទ៖ +៨៥៥ (0) ១២ ៤៨៣ ២៨៣
អ៊ីមែល៖ neth.phektra@eccc.gov.kh



Original EN: 01699217-01699217